ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែប
ប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)
**លេខាធិការដ្ឋាន**

លេខៈ ០៤៦ គ.ជ.អ.ប/ល.ធ.ក/គ.ជ.អ.ប

រាជធានីភ្នំពេញ, ថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៦

## គោរពជូន

**ឯកឧត្តមអភិបាលនៃគណៈអភិបាលខេត្ត បន្ទាយមានជ័យ បាត់ដំបង កំពង់ធំ កោះកុង**
**មណ្ឌលគិរី រតនៈគិរី ព្រៃវែង ពោធិ៍សាត់ សៀមរាប ត្បូងឃ្មុំ ស្វាយរៀង កំពត ក្រចេះ និងខេត្តប៉ៃលិន**

**កម្មវត្ថុ** ៖ អំពីការបញ្ចូលផែនការសកម្មភាពរួមស្ដីពីការងារគណនេយ្យភាពសង្គម(ផ.ស.រ.គ) ទៅក្នុងដំណើរការកសាងកម្មវិធីវិនិយោគប្រចាំឆ្នាំឃុំ សង្កាត់ និងការរៀបចំបង្កើតគណៈកម្មាធិការផែនការគណនេយ្យភាពរួមស្ដីពីការងារគណនេយ្យភាពសង្គមនៅថ្នាក់ឃុំ សង្កាត់ សម្រាប់ការអនុវត្តការងារគណនេយ្យភាពសង្គមនៅថ្នាក់ក្រោមជាតិ។

**យោង** ៖ ផែនការអនុវត្តគណនេយ្យភាពសង្គមសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។

សេចក្ដីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ សូមជម្រាបជូនឯកឧត្តមជ្រាបថា៖ ផែនការអនុវត្តគណនេយ្យភាពសង្គមសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិឆ្នាំ២០១៦-២០១៨ ត្រូវបានអនុម័តដាក់ឲ្យអនុវត្ត កាលពីខែកុម្ភៈ ឆ្នាំ២០១៦។ ក្នុងផែនការអនុវត្តនេះ មានបែងចែកជាបួនសមាសភាគ និងតម្រូវឲ្យមានការអនុវត្តរួមគ្នានៅតាមស្រុកគោលដៅនីមួយៗ រវាងផ្នែកផ្គត់ផ្គង់(រាជរដ្ឋាភិបាល) និងផ្នែកតម្រូវការ (ប្រជាពលរដ្ឋតាមរយៈអង្គការសង្គមស៊ីវិល) ដែលផ្នែកផ្គត់ផ្គង់ត្រូវទទួលខុសត្រូវចំបងលើសមាសភាគទី១ (ភាពងាយទទួលបានព័ត៌មាននានា និងព័ត៌មានថវិកា) ចំណែកឯផ្នែកតម្រូវការទទួលខុសត្រូវចំបងលើសមាសភាគទី២ (ស្ដីពីការត្រួតពិនិត្យតាមដានដោយប្រជាពលរដ្ឋ)។ នៅចុងបញ្ចប់នៃដំណើរការអនុវត្តសកម្មភាពក្នុងសមាសភាគទី២ ទាំងសហគមន៍ឬអ្នកប្រើប្រាស់សេវា(ប្រជាពលរដ្ឋ) និងអង្គភាពផ្ដល់សេវា (រដ្ឋបាលឃុំ មណ្ឌលសុខភាព និងសាលាបឋមសិក្សា) ត្រូវរៀបចំផែនការសកម្មភាពព្រមព្រៀងគ្នាមួយ ហៅថា "***ផែនការសកម្មភាពរួមស្ដីពីការងារគណនេយ្យភាពសង្គម(ផ.ស.រ.គ)***" ដែលផែនការសកម្មភាពនោះ ត្រូវមានការព្រមព្រៀងពីបណ្ដាអ្នកពាក់ព័ន្ធក្នុងដំណើរការនៃកិច្ចប្រជុំរួមគ្នា។ ផ្អែកតាមគោលការណ៍ដែលបានកំណត់ក្នុងផែនការអនុវត្តគណនេយ្យភាពសង្គម បន្ទាប់ពីរៀបចំរួចរាល់ផ.ស.រ.គនេះ តម្រូវឲ្យមានការដាក់បញ្ចូលទៅក្នុងដំណើរការកសាងកម្មវិធីវិនិយោគប្រចាំឆ្នាំឃុំសង្កាត់។

ដើម្បីធានាបាននូវនិរន្តភាពក្នុងការអនុវត្តនៅមូលដ្ឋាន ផែនការអនុវត្តគណនេយ្យភាពសង្គមបានចង្អុលបង្ហាញផងដែរនូវយន្តការសម្រាប់ការត្រួតពិនិត្យតាមដានលើការអនុវត្តផែនការសកម្មភាពរួមស្ដីពីគណនេយ្យភាពសង្គម ដោយបានកំណត់ឲ្យឃុំនីមួយៗត្រូវរៀបចំបង្កើតគណៈកម្មាធិការរួមមួយហៅថា "***គណៈកម្មាធិការផែនការសកម្មភាពរួមស្ដីពីការងារគណនេយ្យភាពសង្គម***" ដែលមានសមាសភាពមកពី អង្គភាពផ្ដល់សេវា មានរដ្ឋបាលឃុំ មណ្ឌលសុខភាព សាលាបឋមសិក្សា តំណាងសហគមន៍ និងអ្នកពាក់ព័ន្ធមួយចំនួនទៀត។

អាស្រ័យហេតុនេះ សូមឯកឧត្តមអភិបាលនៃគណៈអភិបាលខេត្ត មេត្តាជ្រាប និងជូនដំណឹងឲ្យដល់ក្រុមប្រឹក្សាឃុំ សង្កាត់គោលដៅពិនិត្យ ពិចារណាដាក់បញ្ចូលផែនការសកម្មភាពរួមស្ដីពីការងារគណនេយ្យភាពសង្គមទៅក្នុងដំណើរការកសាងកម្មវិធីវិនិយោគឃុំ និងរៀបចំបង្កើតគណៈកម្មាធិការផែនការសកម្មភាពរួមស្ដីពីការងារគណនេយ្យភាព សង្គមដូចមានក្នុងឯកសារជំនួយស្មារតីជូនភ្ជាប់មកជាមួយតាមការគួរ។

សូមឯកឧត្តម មេត្តាទទួលនូវការគោរពរាប់អានដ៏ស្មោះស្ម័គ្រអំពីខ្ញុំ។

ជ. **ប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប**

ចម្លងជូន៖

- រដ្ឋបាលខេត្ត ស្រុក និងឃុំគោលដៅ
- អង្គការ CARE, Save the Children, RACHA
- អង្គការ World Vision និងអង្គការ Star Kampuchea
  "ដើម្បីសហការអនុវត្ត"
- ឯកសារកាលប្បវត្តិ